**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ:..៥០៣...សហវ.....

# ប្រកាស

## ស្តីពី

## ការកែតំរូវប្រកាសលេខ ១៩៣ សហវ.ប្រក

## ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការកំណត់សាធនភាពនៃក្រុមហ៊ុនធានារ៉ាប់រង

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង

-បានឃើញអនុក្រឹត្យលេខ ១០៦/អនក្រ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០០១ ណែនាំការអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង

-បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

-បានឃើញអនុក្រឹត្យលេខ ៧៨/អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០៤ ស្ដីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញប្រកាសលេខ ១៩៣ សហវ.ប្រក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្ដីពីការកំណត់សាធនភាពនៃក្រុមហ៊ុនធានារ៉ាប់រង

-បានឃើញភាពចាំបាច់នៃការងារគ្រប់គ្រង

## សំរេច

**ប្រការ ១:** ប្រការ ៨ នៃប្រកាសលេខ ១៩៣ សហវ.ប្រក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្ដីពីការកំណត់សាធនភាពនៃក្រុមហ៊ុនធានារ៉ាប់រង ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ២:** សាធនភាពនៃក្រុមហ៊ុនធានារ៉ាប់រង ត្រូវអនុវត្តទៅតាមច្បាប់ស្ដីពីការធានារ៉ាប់រង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម /០៧០០/០២ ចុះ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដូចមានសារាចរណែនាំលេខ ០០៩ សហវ.ឧហ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០២ ស្ដីពីការផ្ដល់អាជ្ញាប័ណ្ណធានារ៉ាប់រងបណ្ដោះអាសន្ន ។

**ប្រការ ៣:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ទាំងអស់ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងក្រុមហ៊ុនធានារ៉ាប់រង និងភ្នាក់ងារធានារ៉ាប់រងទាំងអស់ ដែលកំពុងធ្វើសកម្មភាពអាជីវកម្មធានារ៉ាប់រង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ ថ្ងៃទី០៨ ខែសីហា ឆ្នាំ ២០០៥

**គាត ឈន់**

**កន្លែងទទួល:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី

«ដើម្បីជូនជ្រាប»

- ដូចមានក្នុងប្រការ ៣

«ដើម្បីអនុវត្ត»

- ឯកសារ-កាលប្បវត្តិ